# ឯ.ឧ. ទេសរដ្ឋមន្ត្រី អៀង មូលី អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ គណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជា

នាវេលាម៉ោង ២រសៀល ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ នៅទីស្នាក់ការកណ្តាលអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺ អេដស៍ មានរៀបចំកិច្ចប្រជុំលើកទី១ក្នុងឆ្នាំ២០១៦ របស់គណៈកម្មាធិការសម្រ បសម្រួលមូលនិធិសកលប្រចាំកម្ពុជា (CCC) ក្រោមអធិបតីភាពរបស់ **ឯ.ឧ. ទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំ កម្ពុជា។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះរួមមាន៖

- អ្នកតំណាងមកពី ក្រសួងពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា
- តំណាងអង្គការសហប្រជាជាតិមកពី WHO, UNAIDS.
- ដៃគូអភិវឌ្ឍន៍ដែលមាន តំណាងស្ថានទូតបារាំង អាល្លឺម៉ង់ និង សហរដ្ឋអាមេរិក
- តំណាងអ្នករស់នៅជាមួយជំងឺ ជំងឺអេដស៍ របេង គ្រុនចាញ់
- តំណាងសង្គមស៊ីវិលដែលមាន អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធនឹងការប្រយុទ្ធនឹងជំងឺអេដស៍ របេង គ្រុនចាញ់ គ្រឹះស្ថានឧត្តមសិក្សា និង វិស័យឯកជន។

កិច្ចប្រជុំបានផ្តោតសំខាន់លើ ការបោះឆ្នោតជ្រើសរើសប្រធានគណៈកម្មកាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជា សំរាប់អណត្តិពីរឆ្នាំបន្ទាប់ (២០១៦-២០១៧)។

សមាសភាព គណៈកម្មកាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជាដែលបានអញ្ជើញចូលរួមប្រជុំចំនួន២០នាក់។ សមាជិកដែលមានសិទ្ធចូលរួមបោះឆ្នោតជ្រើសរើសប្រធានគណៈកម្មការ មានចំនួន ២០នាក់។

លទ្ធផលនៃការបោះឆ្នោតជ្រើសរើសទទួលបានលទ្ធផលដូចតទៅ បេក្ខជនដែលបានចូលរួមឈរឈ្មោះជាប្រធានគណៈកម្មកាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជា មានចំនួនតែម្នាក់ គឺ ឯកឧត្តម ទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ក្រោយពីបានបោះឆ្នោត បេក្ខភាពឈរឈ្មោះជាប្រធានរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី អៀង មូលី ទទួលបានសំលេងឆ្នោតគាំទ្រចំនួន២០ លើចំនួនសំលេងដែលបានបោះឆ្នោតសរុប២០ ឬ ១០០%។ លទ្ធផលនៃការបោះឆ្នោត បានបង្ហាញថា សមាជិក សមាជិការបានឯកភាពទាំងស្រុង និងផ្តល់ទំនុកចិត្ត ដល់ការខិតខំប្រឹងប្រែង និងលទ្ធផលជោគជ័យ

នៃការដឹកនាំកន្លងមករបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី អៀង មូលី ដោយ ឯកឧត្តម ត្រូវបាន បោះឆ្នោតជ្រើសរើសដោយសំលេងច្រើនលើសលុប ជាប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំកម្ពុជាសំរាប់អណាត្តិថ្មី ឆ្នាំ២០១៦ ២០១៧នេះ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនដល់ ឯកឧត្តម លោក លោកស្រី ជាសមាជិកគណៈកម្មាធិការទាំងអស់ដែលបានផ្តល់ការទុកចិត្ត បោះឆ្នោតជ្រើសរើស ឯកឧត្តម ជាប្រធានសារជាថ្មីម្តងទៀត ដែលអនុញ្ញាតិអោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី បន្តដឹកនាំគណៈកម្មាធិការសំរាប់អណាត្តិថ្មី និងចូលរួមនៅក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរាលដាលនៃមេរោគ អេដស៍ របេង គ្រុនចាញ់ ជាបន្តទៀត។

ជាមួយនោះ លោកវេជ្ជបណ្ឌិត Dong Il ANH ប្រធានអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា និង លោក ឈុំ សុផា តំណាងមកពីអង្គការក្រៅរដ្ឋាភិបាល ក៏បានជាប់ឆ្នោតជាអនុប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលកម្ពុជាដែរ។